# វិន័យខាងឯសេចក្ដីស្រលាញ់
# Discipline of Love

**សេចក្ដីសង្ខេប:**

វិន័យខាងឯសេចក្ដីស្រលាញ់គឺជាវិន័យមួយខាងវិញ្ញាណ និងជាឧបករណ៍មួយដ៏មានប្រសិទ្ធភាពនៅក្នុងការបង្កើតសិស្ស ដែលត្រូវបានបង្កើតឡើងដើម្បីជួយអ្នកដើរតាមព្រះគ្រីស្ទឱ្យហាត់បង្ហាញចេញសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ តាមរយៈការបម្រើអ្នកដទៃទៀត។ រូបអង្គរបស់ព្រះជាម្ចាស់ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញច្បាស់បំផុតនៅក្នុងមនុស្សតាមរយៈការបម្រើដោយហ៊ានលះបង់។ អ្នកជឿគួរតែដឹងឱ្យកាន់តែច្រើនថា ខ្លួនត្រូវឆ្លុះបញ្ចាំងឱ្យឃើញអត្តចរិតរបស់ព្រះជាម្ចាស់នៅក្នុងផ្នែកទាំងបួនដែលព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ (ប្រាជ្ញា សាច់ឈាម វិញ្ញាណ និងសង្គម) នៅក្នុងពិភពដែលពួកគេរស់នៅ (គ្រួសារ ពួកជំនុំ និងសហគមន៍)។

**គំនិតចម្បង:**

១. យើងត្រូវបង្កើតឡើងឱ្យចំរូបអង្គរបស់ព្រះជាម្ចាស់។ ការបម្រើគឺជាការឆ្លុះបញ្ចាំងច្បាស់ជាងគេឱ្យឃើញរូបអង្គរបស់ព្រះជាម្ចាស់នៅក្នុងមនុស្ស។

២. ព្រះយេស៊ូវចុះមកប្រសូត ជាសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ដែលបង្ហាញចេញតាមរយៈការបម្រើ។ យើងត្រូវត្រលប់ដូចជារូបអង្គរបស់ព្រះគ្រីស្ទ ជាអ្នកបម្រើដោយស្ម័គ្រចិត្ត ដោយស្ដាប់បង្គាប់ និងដោយស្រលាញ់។

៣. សេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ត្រូវបានបង្ហាញចេញតាមរយៈការស្ដាប់បង្គាប់របស់យើងនៅក្នុងការបម្រើអ្នកដទៃទៀតនៅតាមគ្រប់ផ្នែកទាំងអស់នៅក្នុងជីវិត។

៤. វិន័យចាំបាច់ខ្លាំងណាស់សម្រាប់ការបណ្ដុះបណ្ដាល និងការរីកចម្រើនឡើងខាងឯការគោរពប្រតិបត្តិដល់ព្រះ។ យើងត្រូវបណ្ដុះបណ្ដាលខ្លួនយើងឱ្យបម្រើ។

៥. យើងអាចរៀបចំផែនការ អនុវត្ត ឆ្លុះបញ្ចាំង និងមានទំនួលខុសត្រូវនៅក្នុងការបម្រើរបស់យើង។

**លទ្ធផល:**

១. ឥឡូវនេះ:

ក. យល់ និងនិយាយប្រាប់គំនិតចម្បងរបស់មេរៀន ដោយប្រើពាក្យរបស់ខ្លួនគេ។

ខ. រៀបចំផែនការ និងអនុវត្តកិច្ចការដែលជាវិន័យខាងឯសេចក្ដីស្រលាញ់នៅក្នុងរយៈពេល ២៤ ម៉ោងក្រោយ។

២. ទៅមុខទៀត

ក. ទទួលស្គាល់ថា ការបម្រើដោយសេចក្ដីស្រលាញ់គឺជាការបង្ហាញចេញដ៏សំខាន់ជាងគេឱ្យឃើញរូបអង្គរបស់ព្រះជាម្ចាស់ និងប្ដេជ្ញាចិត្តអនុវត្តវិន័យខាងឯសេចក្ដីស្រលាញ់ឱ្យបានពេញមួយវដ្ដនៅក្នុងរយៈពេលបីខែក្រោយ។

ខ. ធ្វើការជាអ្នកដឹកនាំដើម្បីបង្រៀន លើកទឹកចិត្ត និងដឹកនាំអ្នកដទៃទៀតឱ្យរស់នៅក្នុងជីវិតដែលមានការលត់ដំខាងឯការស្រលាញ់ដល់អ្នកដទៃ។

# វិន័យខាងឯសេចក្ដីស្រលាញ់

## គ្រោងមេរៀន

## ១. រំឮកមេរៀនឡើងវិញ

## ២. សេចក្ដីផ្ដើម

## ៣. ខគម្ពីរគន្លឹះ: ១ ធីម៉ូថេ ៤:៧-៨

ក. តើមនុស្សបង្ហាត់ខ្លួនឱ្យគោរពប្រតិបត្តិដល់ព្រះយ៉ាងដូចម្ដេច?

ខ. តើមានពាក្យអ្វីខ្លះទៀតដែលពាក់ព័ន្ធជាមួយនឹងការបង្ហាត់?

គ. តើវិន័យចាំបាច់សម្រាប់ការរីកចម្រើនឡើងដែរឬទេ?

## ៤. តើព្រះចង់ឱ្យកូនរបស់ព្រះអង្គបានដូចជាព្រះគ្រីស្ទដែរឬទេ?

- រ៉ូម ៨:២៩

## ៥. តើយើងមានតួនាទីយ៉ាងដូចម្ដេចនៅក្នុងការត្រួលប់នេះ?

- ភីលីព ២:១២

- ២ ធីម៉ូថេ ៤:២

- យ៉ូហាន ១៥:៤-៥

## ៦. តើព្រះមានតួនាទីយ៉ាងដូចម្តេចនៅក្នុងការត្រួលប់របស់យើងនេះ?

- ភីលីព ២:១៣

- អេភេសូរ ៣:២០

## ៧. តើបង្កើតឱ្យមានរូបអង្គដូចព្រះមានន័យយ៉ាងដូចម្តេច? លោកុប្បត្តិ ១:២៧

- លទ្ធភាពបង្កើត

- លទ្ធភាពប្រើពាក្យសំដី

- ទំនាក់ទំនងដែលមានគោលបំណង

- ជម្រើសខាងសីលធម៌

- ផ្នែកនៃរូបអង្គរបស់ព្រះជាម្ចាស់ដែលយើងចង់ឆ្លុះបញ្ចាំងនៅក្នុងយើង៖
    - ម៉ាថាយ ២០:២៨
    - ភីលីព ២:៥-៩

## ៨. ការអភិវឌ្ឍន៍ឡើងចាប់ផ្តើមជាមួយខ្ញុំ

ក. តើការបម្រើ និងសេចក្តីស្រលាញ់មានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្តេច? (១ យ៉ូហាន ៣:១៦-១៨)

## ៩. ការពង្រឹងគំនិតគន្លឹះឡើងវិញ

## ១០. ផែនការអនុវត្តន៍

- ថ្មី
- ច្បាស់លាស់
- ជាក់លាក់
- ចែកចាយ

# ការណែនាំសម្រាប់អ្នកដឹកនាំក្រុមតូចអំពីវិន័យខាងឯសេចក្តីស្រលាញ់

១. រំលឹកឡើងវិញការណែនាំសម្រាប់អ្នកដឹកនាំក្រុមតូច និងមេរៀន។

២. មុនពេលដឹកនាំក្រុម សូមបំពេញ និងកត់ត្រាចូលទិន្នានុប្បវត្តិវិន័យមួយខាងឯសេចក្តីស្រលាញ់នៅក្នុងប្រភេទនិមួយៗ ដែលមានគ្រួសារ ពួកជំនុំ និងសហគមន៍។

៣. ប្រើពេលបង្រៀននៅក្នុងពេលជួបជុំមួយ ដើម្បីណែនាំអំពីវិន័យខាងឯសេចក្តីស្រលាញ់ (**វខស**) ប្រាប់ដល់ក្រុមតូចរបស់លោកអ្នក (សូមមើលមេរៀន ១-៤)។ ប្រគល់កិច្ចការឱ្យសមាជិកម្នាក់ៗរៀបចំផែនការ អនុវត្ត និងកត់ត្រា **វខស** មួយចូលទិន្នានុប្បវត្តិ មុនការជួបជុំលើកក្រោយ។

៤. កែប្រែកាលវិភាគដែលផ្តល់ជូនឱ្យត្រូវតាមតម្រូវការក្រុមរបស់លោកអ្នក ប៉ុន្តែត្រូវឱ្យប្រាកដថា មានពេលវេលាគ្រប់គ្រាន់នៅក្នុងអំឡុងពេលការជួបជុំបន្ទាប់ទៀត ដើម្បីសង្ខេបប្រាប់ **វខស** ដែលបានធ្វើ និងរៀបចំផែនការសម្រាប់ **វខស** បន្ទាប់ទៀត។

៥. សម្របសម្រួលការពិភាក្សានៅក្នុងចំណោមសមាជិកក្រុមអំពី **វខស** និងលើកទឹកចិត្តពួកគេឱ្យផ្តល់គំនិតយោបល់ និងការលើកទឹកចិត្តដល់គ្នាទៅវិញទៅមក។

៦. ផ្តល់ការដឹកនាំ ប្រសិនបើសមាជិកក្រុមមិនបានផ្តល់គំនិតយោបល់ និងការលើកទឹកចិត្តដល់គ្នាទៅវិញទៅមកទេ។

៧. រក្សាទុកនូវកំណត់ត្រាអំពីការហាត់អនុវត្ត វខស របស់សមាជិកម្នាក់ៗ (សូមមើល"កំណត់ត្រាសម្រាប់អ្នកដឹកនាំក្រុមតូច"ដែលមាននៅទំព័របន្ទាប់)។

៨. ហាត់អនុវត្តផ្ទាល់ខ្លួនសម្រាប់ វខស យ៉ាងហោចណាស់ឱ្យបានមួយនៅចន្លោះការជួបប្រជុំនិមួយៗ។

៩. ទាក់ទងសមាជិកក្រុមម្នាក់ៗនៅចន្លោះពេលនៃការជួបប្រជុំ ដើម្បីលើកទឹកចិត្ត និងគាំទ្រ។

# គំរូកាលវិភាគរយៈពេល ២ម៉ោងសម្រាប់ក្រុមតូច

| | |
|---|---|
| ៣០ នាទី | ការប្រកបគ្នា |
| ៣០ នាទី | ការបង្រៀន |
| ១៥ នាទី | ការធ្វើទីបន្ទាល់អំពីវិន័យខាងឯសេចក្តីស្រលាញ់ |
| ១៥ នាទី | ការគាំទ្រ និងការអធិស្ឋានពីសមាជិកក្រុម |
| ១៥ នាទី | ការរៀបចំផែនការសម្រាប់ការអនុវត្តន៍បន្ទាប់ទៀត |
| ១៥ នាទី | ការចែកចាយ និងការអធិស្ឋាន |
| --- | អ្នកដឹកនាំក្រុមទាក់ទងសមាជិកនៅចន្លោះពេលនៃការជួបប្រជុំ |
| --- | អ្នកដឹកនាំក្រុមអធិស្ឋានទូលអង្វរ និងអនុវត្តខ្លួនឯង |

# កំណត់ត្រាសម្រាប់អ្នកដឹកនាំក្រុមតូច

## សម្រង់វត្តមាន និងទិន្នានុប្បវត្តិ

**កាលបរិច្ឆេទចាប់ផ្ដើម:________ កាលបរិច្ឆេទបញ្ចប់:________**

អ្នកដឹកនាំ:____________________ ក្រុម:____________________

សមាជិកទី ១:____________________

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ២:____________________

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ៣:____________________

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ៤:____________________

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ៥:____________________

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ៦:____________________

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ៧:____________________

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ៨:____________________

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ១០:

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ១១:

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ១២:

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ១:

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

សមាជិកទី ១:

| ការជួបជុំ # | ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| វត្តមាន | | | | | | | | | | | | | |
| វខស | | | | | | | | | | | | | |

# ឯកសារមេរៀនទី ១
# វិន័យខាងឯសេចក្ដីស្រលាញ់

**ខគម្ពីរគន្លឹះ: ១ ធីម៉ូថេ ៤:៧-៨**

*...ចូរបង្ហាត់ខ្លួនខាងឯសេចក្តីគោរពប្រតិបត្តិដល់ព្រះវិញ ដ្បិតការបង្ហាត់ខ្លួនប្រាណ នោះមានប្រយោជន៍តែបន្តិចទេ តែមានសេចក្តីសន្យាឱ្យបានជីវិតនៅជាប់ឥឡូវនេះ ហើយទៅខាងនាយផង ។*

*១ ធីម៉ូថេ ៤:៧-៨*

**សំណួរស្វែងយល់**

១. តើមនុស្សបង្ហាត់ខ្លួនឱ្យគោរពប្រតិបត្តិដល់ព្រះយ៉ាងដូចម្ដេច?

២. តើមានពាក្យអ្វីខ្លះទៀតដែលពាក់ព័ន្ធជាមួយនឹងការបង្ហាត់?

៣. តើវិន័យចាំបាច់សម្រាប់ការរីកចម្រើនឡើងដែរឬទេ?

**<u>ខគម្ពីរគាំទ្រ និងសំណួរស្វែងយល់</u>**

១. តើអ្នកគិតថា ហេតុអ្វីបានជា ព្រះជាម្ចាស់ចង់ឱ្យកូនរបស់ព្រះអង្គត្រលប់ដូចជាព្រះគ្រីស្ទ?

សូមអាន: រ៉ូម ៨:២៩

២. តើព្រះមានតួនាទីយ៉ាងដូចម្ដេច ហើយយើងមានតួនាទីយ៉ាងដូចម្ដេចនៅក្នុងការត្រលប់ដូចជាព្រះគ្រីស្ទ?

សូមអាន: ភីលីព ២:១២-១៣, អេភេសូរ ៣:២០, យ៉ូហាន ១៥:៤-៥

៣. យោងទៅតាមខគម្ពីរទាំងនេះ តើផ្នែកណានៃរូបអង្គរបស់ព្រះជាម្ចាស់ និងរបស់ព្រះគ្រីស្ទ គួរតែឆ្លុះបញ្ចាំងឱ្យឃើញនៅក្នុងយើង?

សូមអាន: ម៉ាថាយ ២០:២៨, រ៉ូម ១៥:៨-៩, ភីលីព ២:៦-៨

៤. តើការបម្រើ និងសេចក្ដីស្រលាញ់មានទំនាក់ទំនងជាមួយគ្នាយ៉ាងដូចម្ដេច?

សូមអាន: ១ យ៉ូហាន ៣:១៦

# ផែនការអនុវត្តន៍

## ការស្រាវជ្រាវ និងការសញ្ជឹងគិត

រំលឹកឡើងវិញឯកសារមេរៀនសម្រាប់សិស្សពីទី ២ ដល់ទី ៤។

## ការសម្រេចចិត្ត និងការទូលអង្វរ

ចែកចាយការប្តេជ្ញាចិត្តរបស់លោកអ្នកជាមួយអ្នកផ្សេងទៀត។ បន្ទាប់មក អធិស្ឋានឱ្យគ្នាទៅវិញទៅមក។

# របាយការណ៍អំពីការអនុវត្តន៍

ចូរត្រៀមខ្លួនដើម្បីរៀបរាប់របាយការណ៍នៅពេលចាប់ផ្តើមការរៀនលើកក្រោយទៀត។

# ឯកសារមេរៀនទី ២

# គំរូក្រឡាចត្រង្គ

| ផ្នែកនៃសេចក្ដីត្រូវការ ➔<br>បរិបទសម្រាប់ការបម្រើ 🡻 | ប្រាជ្ញា | សាច់ឈាម | វិញ្ញាណ | សង្គម |
|---|---|---|---|---|
| **គ្រួសារ** | **១.** *ថ្ងៃ០២ ឧសភា* ☑<br>*ពិភាក្សាអំពីសុភាសិតមួយ និងរបៀបអនុវត្តសុភាសិតនោះនៅក្នុងពេលស្ញៀមស្ងាត់សម្រាប់គ្រួសាររាល់តែថ្ងៃពេញមួយសប្ដាហ៍នេះ។* | **២.** *ថ្ងៃ១០ ឧសភា* ☑<br>*លាងចានក្រោយពីបរិភោគអាហារពេលល្ងាចរួចហើយ ចំនួនបីដងនៅសប្ដាហ៍នេះ។* | **៣.** *ថ្ងៃ១៦ ឧសភា* ☑<br>*សុំកូនផ្សេងទៀតឱ្យដឹកនាំការអធិស្ឋានសម្រាប់គ្រួសាររាល់តែថ្ងៃ។* | **៤.** *ថ្ងៃ២៧ ឧសភា* ☑<br>*ចេញទៅដើរលេងខាងក្រៅជាមួយប្ដី ឬប្រពន្ធខ្ញុំដោយមិនយកកូនទៅជាមួយ។* |
| **ពួកជំនុំ** | **៥.** *ថ្ងៃ០៣ មិនថុនា* ☑<br>*ផ្ដោតពេលស្ញៀមស្ងាត់ផ្ទាល់ខ្លួននៅសប្ដាហ៍នេះទៅលើការអនុវត្តន៍សេចក្ដីអធិប្បាយនៅសប្ដាហ៍នេះ។* | **៦.** *ថ្ងៃ១០ មិថុនា* ☑<br>*ស្ម័គ្រចិត្តជួយនៅក្នុងការិយាល័យពួកជំនុំនៅចុងសប្ដាហ៍។* | **៧.** *ថ្ងៃ១៧ ឧសភាព* ☑<br>*ចំណាយពេល ១៥នាទីរៀងរាល់ថ្ងៃនៅសប្ដាហ៍នេះដើម្បីអធិស្ឋានឱ្យគ្រូគង្វាល និងអ្នកដឹកនាំរបស់យើង។* | **៨.** *ថ្ងៃ២៨ មិថុនា* ☑<br>*នាំយកកូនដែលមានតែម្ដាយ ឬមានតែឪពុកចេញទៅដើរលេងខាងក្រៅ។* |
| **សហគមន៍<br>ពិភពរបស់អ្នក ឬ<br>ពិភពដែលមានវប្បធម៌ផ្សេង** | **៩.** *ថ្ងៃ០១ កក្កដា* ☑<br>*ទៅលេងអ្នកដឹកនាំដែលត្រូវបានរើសតាំងដើម្បីរៀនអំពីសេចក្ដីត្រូវការនៅក្នុងសហគមន៍ និងសួរអំពីរបៀបដែលខ្ញុំអាចជួយបាន។* | **១០.** *ថ្ងៃ០៩ កក្កដា* ☑<br>*រើសសំរាមនៅតាមផ្លូវរាល់ថ្ងៃនៅសប្ដាហ៍នេះ នៅពេលដែលខ្ញុំដើរទៅធ្វើការ។* | **១១.** *ថ្ងៃ១៦ កក្កដា* ☑<br>*សួរអ្នករួមការងារជាមួយខ្ញុំពីរបៀបដែលខ្ញុំអាចអធិស្ឋានឱ្យកូនប្រុសរបស់គាត់ និងអធិស្ឋានសម្រាប់កូននោះរាល់ថ្ងៃនៅសប្ដាហ៍នេះ។* | **១២.** *ថ្ងៃ២៥ កក្កដា* ☑<br>*យកនំ និងសំបុត្រថ្លែងអំណរគុណទៅឯស្ថានីយប៉ូលិស។* |

*** នៅក្នុងកិច្ចការ ១:៨ ព្រះយេស៊ូវបានប្រាប់អ្នកដើរតាមព្រះអង្គថា ពួកគេនឹងធ្វើជាទីបន្ទាល់របស់ព្រះអង្គនៅក្រុងយេរូសាឡិម (កន្លែងដែលពួកគេនៅ) នៅស្រុកយូដា ស្រុកសាម៉ារី និងរហូតដល់ចុងបំផុតនៃផែនដី គឺរង្វង់ភូមិសាស្ត្រ និងរង្វង់វប្បធម៌កាន់តែរីកធំឡើងៗ។**

**គ្រួសារ** រួមមានប្ដីប្រពន្ធ កូន ឪពុកម្ដាយ បងប្អូនបង្កើត បងប្អូនថ្លៃ គ្រួសារសាច់ឆ្ងាយ អ្នករួមបន្ទប់ មិត្តភក្ដិជិតស្និទ្ធ។
**ពួកជំនុំ** *រួមមានអវយវៈទាំងអស់នៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ* ដែលមានគ្រូគង្វាល ក្រុមផ្សេងៗនៅក្នុងពួកជំនុំ អគារពួកជំនុំ។

**"សហគមន៍"** រួមមានកន្លែងធ្វើការរបស់យើង សាលារៀន សកម្មភាពប្រចាំថ្ងៃ អ្នកជិតខាង ទាំងនេះគឺជាកន្លែងដែលយើងចំណាយពេលច្រើន ប៉ុន្តែលើកលែងគ្រួសារ ពួកជំនុំ និងអ្នកជឿចេញ។ "**ពិភពដែលមានវប្បធម៌ផ្សេង**" រួមមានអ្នកដែលមានសេចក្ដីត្រូវការពិសេស (កុមារកំព្រា អ្នកទោស ចាស់ជរា ក្រុមមនុស្សដែលមិនទាន់បានឮដំណឹងល្អ) និងបញ្ហាផ្សេងៗថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

**សរសេរកាលបរិច្ឆេទដែលបានបញ្ចប់: __________ គូសលើប្រអប់ ☑ នៅពេលដែលបានធ្វើលំហាត់រួចហើយ**

# ឯកសារមេរៀនទី ៣
# គំរូផែនការ

**លេខរៀង:** *១* **កាលបរិច្ឆេទ:** *ថ្ងៃទី ០៥ ខែកក្កដា*

**បរិបទ / ផ្នែក:** *គ្រួសារ - ប្រាជ្ញា*

**១. តើសេចក្តីត្រូវការគឺជាអ្វី ហើយតើខ្ញុំនឹងធ្វើអ្វី?**

ខ្ញុំត្រូវដឹកនាំគ្រួសាររបស់ខ្ញុំនៅក្នុងពេលស្ញៀមស្ងាត់ដែលមានជាទៀងទាត់ ។ ខ្ញុំនឹងចាប់ផ្តើមនៅថ្ងៃច័ន្ទនេះ ដោយស្ញៀមស្ងាត់សញ្ជឹងគិតអំពីខគម្ពីរមួយនៅក្នុងកណ្ឌគម្ពីរសុភាសិត ។

**២. ជាមួយ ឬសម្រាប់អ្នកណា?** គ្រួសាររបស់ខ្ញុំ ។

**៣. នៅពេលណា?** ថ្ងៃច័ន្ទ

**៤. នៅកន្លែងណា?** នៅផ្ទះ ពេលបរិភោគអាហារពេលល្ងាច

---

## ផែនការ

**លេខរៀង:** ______ **កាលបរិច្ឆេទ:** ______________

**បរិបទ / ផ្នែក:** ___________________

**១. តើសេចក្តីត្រូវការគឺជាអ្វី ហើយតើខ្ញុំនឹងធ្វើអ្វី?**

**២. ជាមួយ ឬសម្រាប់អ្នកណា?**

**៣. នៅពេលណា?**

**៤. នៅកន្លែងណា?**

# ឯកសារមេរៀនទី ៤
# ទិន្នានុប្បវត្តិ

**កាលបរិច្ឆេទៈ** ______________ **បិរបទ / ផ្នែកៈ** __________________

**១. តើអ្នកបានធ្វើអ្វី?**

**២. តើមានលទ្ធផលអ្វីខ្លះ?**

**៣. តើអ្នករៀនបានអ្វី?**

| **ជំហាននៅក្នុងការធ្វើលំហាត់** | **ការណែនាំសម្រាប់លំហាត់** |
|---|---|
| ១. អធិស្ឋានរៀបចំខាងវិញ្ញាណ<br>២. ស្គាល់អត្តសញ្ញាណសេចក្តីត្រូវការ<br>៣. បំពេញសេចក្តីត្រូវការ<br>៤. ឆ្លុះបញ្ចាំង និងកត់ចូលក្នុងទិន្នានុប្បវត្តិ<br>**៥.** ធ្វើកំណត់ត្រាលំហាត់ | ១. ចង្អុលបង្ហាញពីព្រះហប្ញទ័យយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ មិនមែនឱ្យគេចាប់អារម្មណ៍នឹងខ្លួនអ្នកទេ។<br>២. មិនដាក់ចេញអ្វីដែលអ្នកទទួលការបម្រើពីអ្នកបដិសេធ។<br>៣. ធ្វើឱ្យអ្នកទៅលើសអ្វីដែលអ្នកធ្វើតាមធម្មតា។<br>៤. តម្រូវឱ្យមានការលះបង់ ប៉ុន្តែមិនបង្វែរអ្នកចេញពីការទទួលខុសត្រូវដែលមានអាទិភាពខ្ពស់ដទៃទៀតទេ។ |

## ឯកសារមេរៀនទី ៥

# វិន័យខាងឯសេចក្ដីស្រលាញ់

| ផ្នែកនៃសេចក្ដីត្រូវការ ➔<br>បរិបទសម្រាប់ ការបម្រើ ↓ | ប្រាជ្ញា | សាច់ឈាម | វិញ្ញាណ | សង្គម |
|---|---|---|---|---|
| គ្រួសារ | 1. ______ ❑ | 2. ______ ❑ | 3. ______ ❑ | 4. ______ ❑ |
| ពួកជំនុំ | 5. ______ ❑ | 6. ______ ❑ | 7. ______ ❑ | 8. ______ ❑ |
| សហគមន៍<br>ពិភពរបស់អ្នក<br>ឬ<br>ពិភពដែលមានវប្បធម៌ផ្សេង | 9. ______ ❑ | 10. _____ ❑ | 11. ______ ❑ | 12. ______ ❑ |

*** នៅក្នុងកិច្ចការ ១:៨ ព្រះយេស៊ូវបានប្រាប់អ្នកដើរតាមព្រះអង្គថា ពួកគេនឹងធ្វើជាទីបន្ទាល់របស់ព្រះអង្គនៅក្រុងយេរូសាឡិម (កន្លែងដែលពួកគេនៅ) នៅស្រុកយូដា ស្រុកសាម៉ារី និងរហូតដល់ចុងបំផុតនៃផែនដី គឺរង្វង់ភូមិសាស្ត្រ និងរង្វង់វប្បធម៌កាន់តែរីកធំឡើងៗ។**

**គ្រួសារ** រួមមានប្តីប្រពន្ធ កូន ឪពុកម្តាយ បងប្អូនបង្កើត បងប្អូនថ្លៃ គ្រួសារសាច់ឆ្ងាយ អ្នករួមបន្ទប់ មិត្តភក្តិជិតស្និទ្ធ។
**ពួកជំនុំ** *រួមមានអវយវៈទាំងអស់នៅក្នុងរូបកាយរបស់ព្រះគ្រីស្ទ* ដែលមានគ្រូគង្វាល ក្រុមផ្សេងៗនៅក្នុងពួកជំនុំ អគារពួកជំនុំ។
"**សហគមន៍**" រួមមានកន្លែងធ្វើការរបស់យើង សាលារៀន សកម្មភាពប្រចាំថ្ងៃ អ្នកជិតខាង ទាំងនេះគឺជាកន្លែងដែលយើងចំណាយពេលច្រើន ប៉ុន្តែលើកលែងគ្រួសារ ពួកជំនុំ និងអ្នកជឿចេញ។ "**ពិភពដែលមានវប្បធម៌ផ្សេង**" រួមមានអ្នកដែលមានសេចក្តីត្រូវការពិសេស (កុមារកំព្រា អ្នកទោស ចាស់ជរា ក្រុមមនុស្សដែលមិនទាន់បានឮដំណឹងល្អ) និងបញ្ហាផ្សេងៗថ្នាក់មូលដ្ឋាន ថ្នាក់តំបន់ ថ្នាក់ជាតិ និងថ្នាក់អន្តរជាតិ។

**សរសេរកាលបរិច្ឆេទដែលបានបញ្ចប់: ___________ គូសលើប្រអប់ ☑ នៅពេលដែលបានធ្វើលំហាត់រួចហើយ**

# វិន័យខាងឯសេចក្ដីស្រលាញ់

របស់សព្វសារពើទាំងអស់ដែលព្រះជាម្ចាស់បានបង្កើតឆ្លុះបញ្ចាំងឱ្យឃើញសិរីល្អរបស់ព្រះអង្គ ប៉ុន្តែព្រះអង្គបានដាក់រូបឆ្លុះបញ្ចាំងច្បាស់ជាងគេបំផុតអំពីព្រះអង្គនៅក្នុងយើង! នៅពេលដែលព្រះជាម្ចាស់បានបង្កើតមនុស្ស ព្រះជាម្ចាស់បានមានបន្ទូលថា "២៦ចូរយើងធ្វើមនុស្សឱ្យដូចជារូបយើង ឱ្យមានភាពដូចយើង ហើយឱ្យមានអំណាចលើត្រីសមុទ្រ សត្វហើរលើអាកាស នឹងសត្វជើង៤ដែលនៅលើផែនដីទាំងមូល ព្រមទាំងសត្វលូនវារដែលវារនៅលើផែនដីផង ២៧ទ្រង់ក៏បង្កើតមនុស្សឱ្យដូចរូបអង្គទ្រង់ គឺបានបង្កើតគេឱ្យចំនឹងរូបអង្គទ្រង់នោះឯង ក៏បង្កើតគេឡើងជាប្រុសជាស្រី" (លោកុប្បត្តិ ១:២៦-២៧)។ ដូច្នេះ ព្រះជាម្ចាស់បានធ្វើមនុស្សឱ្យដូចជារូបព្រះអង្គ ឱ្យមានភាពដូចព្រះអង្គ។

## ត្រូវបានបង្កើតឱ្យចំនឹងរូបអង្គរបស់ព្រះ

លក្ខណៈពិសេសមួយដាច់ដោយឡែកនៃការមានរូបរបស់ព្រះផ្ដល់ឱ្យមានការប្រាប់ជាប្រយោយ៉ាងច្រើន។ ដោយព្រោះតែរូបព្រះនៅក្នុងយើង យើងមានចំណែកនៅក្នុងការផ្សះផ្សា "គ្រប់ទាំងអស់" (កូល៉ុស ១:២០) និងនៅក្នុងការធ្វើឱ្យគេស្គាល់ពីប្រាជ្ញានៃព្រះដ៏មានជាច្រើនយ៉ាងណាស់ ដោយសារពួកជំនុំ (អេភេសូរ ៣:១០)។ យើងក៏មានលក្ខណៈសម្បត្តិដែលមាននៅក្នុងរូបព្រះនៅក្នុងយើងផងដែរ។ ភាពឆ្នៃប្រឌិតរបស់ព្រះអង្គបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈសម្ថភាពរបស់យើងបង្កើតរបស់ថ្មី សូនរូបរាងអនាគតកាល នាំយកភាពមានសណ្ដាប់ធ្នាប់ចេញពីភាពគ្មានសណ្ដាប់ធ្នាប់ និងភាពចលាចល និងធ្វើកិច្ចការ ដូចដែលព្រះជាម្ចាស់បានធ្វើកិច្ចការ។ តាមរយៈលទ្ធភាពខាងភាសារបស់យើង យើងអាចប្រាប់ចេញមកបាននូវគំនិត និងភាពអរូបិយតាមរយៈពាក្យសំដី។ យើងគឺជាស្នាព្រះហស្ដដែលមានទំនាក់ទំនង។ យើងស្គាល់របៀបបង្កើតទំនាក់ទំនងដោយមានចេតនា និងគោលបំណង ជាមួយមនុស្ស ធម្មជាតិ និងការងារ។ យើងបានទទួលជម្រើសខាងសីលធម៌ ដែលសត្វ និងធម្មជាតិមិនមានទេ។ យើងមានសមត្ថភាពចេះសង្កេត និងជ្រើសរើសរវាងអ្វីដែលស្ថាបនា និងអ្វីដែលបំផ្លាញ រវាងអ្វីដែលមានសោភ័ណភាព និងអ្វីដែលគ្មានសោភ័ណភាព។ ហើយយើងមានសមត្ថភាពប្រព្រឹត្តដោយមិនអាត្មានិយមចំពោះអ្នកដទៃៈ ការបម្រើដោយហ៊ានលះបង់។

ការបម្រើដោយសេចក្ដីស្រលាញ់ និងដោយហ៊ានលះបង់ គឺជាលក្ខណៈសំគាល់សំខាន់ជាងគេបំផុតអំពីរូបព្រះ។ ហេតុអ្វី? បើគ្មានលក្ខណៈសម្បត្តិចុងក្រោយនេះទេ លក្ខណៈសម្បត្តិដទៃទៀតអាចទៅជាពុករលួយ។ យើងមានឧទាហរណ៍យ៉ាងច្រើននៅក្នុងពិភពលោករបស់យើងៈ ភាពឆ្នៃប្រឌិតត្រូវបានប្រើដើម្បីបង្កើតគ្រាប់បែកនុយក្លេអ៊ែរ។ លទ្ធភាពខាងភាសារបស់យើងបានបង្កើតភាពអាសអាភាស។ ទំនាក់ទំនងរបស់យើងអាចទៅជាផ្ដាច់ការ។ ជម្រើសខាងសីលធម៌ត្រូវបានប្រើដើម្បីបង្ហាញថា ការបោសសម្អាតជនជាតិមួយ និងការរំលូតកូនគឺជារឿងត្រឹមត្រូវ។

## ត្រូវបានបង្កើតមកសម្រាប់បម្រើ

ព្រះជាម្ចាស់ចង់ឱ្យមនុស្សប្រើលក្ខណៈសម្បត្តិរបស់ព្រះអង្គនៅក្នុងបរិបទបម្រើ ប៉ុន្តែចាប់តាំងពីពេលដែលអ័ដាម និងនាងអេវ៉ាបានជឿការកុហក មនុស្សបានបង្វែរលក្ខណៈសម្បត្តិដែលមាននៅក្នុងរូបព្រះសម្រាប់បម្រើផលប្រយោជន៍ខ្លួនឯង និងបានបង្ខូចរូបព្រះ។ រ៉ូម ១:២២-៣២ ពណ៌នាអ្វីដែលកើតឡើង នៅពេលដែលមនុស្សប្តូររូបព្រះដែលនៅអស់កល្បជានិច្ចយករូបដែលពុករលួយវិញ: សង្គមរបស់យើងពោរពេញទៅដោយអំពើអសីលធម៌ខាងផ្លូវភេទ និងការថ្វាយបង្គំរបស់ដែលត្រូវបានបង្កើត ជំនួសឱ្យព្រះដែលបង្កើត។ យើងមានទំនោរច្រណែន សម្លាប់ជីវិត ឈ្លោះប្រកែក បោកបញ្ឆោត ប្រព្រឹត្តអំពើអសីលធម៌ និយាយដើម និងមួលបង្កាច់។ មានការស្អប់ព្រះ ព្រហើនឈ្លានពាន មានះ កាន់ខ្លួន អួតអាង បង្កើតការអាក្រក់ ហើយមិនស្តាប់បង្គាប់។ រស់នៅតាមរបៀបដែលអាត្មានិយម មិនស្មោះត្រង់ ឥតចិត្ត ឥតយោបល់។ យើងយល់ស្របនឹងអ្នកដទៃដែលធ្វើដូចយើង មិនព្រមជួយគ្នាឱ្យរស់នៅកាន់តែប្រសើរស្របទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ទេ។ យើងបានត្រលប់ទៅជាមនុស្សលេលា។

នៅក្នុងសញ្ញាចាស់មនុស្សមិនអាចមើលឃើញឱ្យបានពេញលេញពីអត្ថន័យនៃការមានរូបអង្គរបស់ព្រះជាម្ចាស់ទេ ជាពិសេសលក្ខណៈសម្បត្តិការបម្រើដោយសេចក្តីស្រលាញ់ និងដោយហ៊ានលះបង់។ ទោះបីយ៉ាងណាក៏ដោយ នៅក្នុងសញ្ញាថ្មី ព្រះជាម្ចាស់បានបើកសំដែងរូបព្រះអង្គនៅតាមរយៈរបៀបដ៏ច្បាស់ពីរ គឺតាមរយៈព្រះយេស៊ូវ និងតាមរយៈពួកជំនុំ។

ដល់ពេលកំណត់ ព្រះជាម្ចាស់បានចាត់ព្រះរាជបុត្រារបស់ព្រះអង្គ ជារូបភាពដ៏គ្រប់លក្ខណ៍ និងដ៏ពេញលេញរបស់ព្រះជាម្ចាស់ (ហេព្រើរ ១:១-៣)។ ជាលើកដំបូង ដែលមនុស្សអាច*មើលឃើញ* ថា ព្រះជាម្ចាស់មានលក្ខណៈយ៉ាងដូចម្តេច។ ពួកគេមិនត្រឹមតែអាចមើលឃើញភាពជាព្រះប៉ុណ្ណោះទេ ថែមទាំងភាពជាមនុស្សដែលស្របទៅតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ដែលបានធ្វើជាគំរូអំពីអត្ថន័យនៃការបង្កើតមកចំរូបអង្គរបស់ព្រះជាម្ចាស់ថែមទៀតផង។ ឥឡូវនេះ នៅពេលដែលយើងមកឯព្រះយេស៊ូវ យើងមើលឃើញលក្ខណៈសម្បត្តិដ៏សំខាន់ជាងគេបំផុតនៅក្នុងរូបអង្គរបស់ព្រះជាម្ចាស់។ យើងមើលឃើញលើសពីភាពគ្រប់លក្ខណ៍ខាងវិញ្ញាណ ថាមពល និងកំឡាំងកាយរបស់ជាងឈើ ប្រាជ្ញាដែលលើសពីប្រាជ្ញារបស់ពួកផារិស៊ី និងជំនាញនៅក្នុងការទំនាក់ទំនងដែលនាំឱ្យគេដឹងថា ព្រះអង្គជាអ្នកបន្ទាបខ្លួន និងបានបំបិទមាត់អ្នកអួតអាង។ នៅក្នុងព្រះយេស៊ូវ យើងមើលឃើញលក្ខណៈសម្បត្តិដ៏សំខាន់ជាងគេបំផុតរបស់រូបព្រះ គឺការបម្រើ។ ព្រះយេស៊ូវផ្ទាល់បានពណ៌នាការបម្រើជាគោលបំណងរបស់ព្រះអង្គ ដោយមានបន្ទូលថា "ដូចជាកូនមនុស្សបានមក មិនមែនអោយគេបំរើលោកទេ គឺនឹងបំរើគេវិញ ហើយនិងអោយជីវិតខ្លួន ទុកជាថ្លៃលោះមនុស្សជាច្រើនផង" (ម៉ាថាយ ២០:២៨)។

សូមពិចារណាផងដែរពីការពណ៌នាដ៏មុតមាំបំផុតរបស់លោកប៉ុលអំពីភាពជាអ្នកបម្រើរបស់ព្រះយេស៊ូវៈ
*"៦ដែលទោះបើទ្រង់ [ព្រះយេស៊ូវ] មានរូបអង្គជាព្រះក៏ដោយ គង់តែមិនបានរាប់សេចក្តីដែលស្មើនឹងព្រះនោះ ទុកជាសេចក្តីដែលគួរកាន់ខ្ជាប់ឡើយ ។ ៧គឺទ្រង់បានលះបង់ព្រះអង្គទ្រង់មកយករូបភាពជាបាវបំរើវិញ ព្រមទាំងប្រសូតមកមានរូបជាមនុស្សផង ៨ហើយដែលឃើញទ្រង់មានភាពជាមនុស្សដូច្នោះ នោះក៏បន្ទាបព្រះអង្គទ្រង់ ទាំងចុះចូលស្តាប់បង្គាប់រហូតដល់ទីមរណៈ គឺទ្រង់ទទួលសុគតជាប់លើឈើឆ្កាងផង"* ( ភីលីព ២:៦-៨ ) ។

ព្រះជាម្ចាស់គឺជាអ្នកបម្រើ ហើយព្រះយេស៊ូវបានធ្វើជាគំរូអំពីភាពជាអ្នកបម្រើនោះ! នៅពេលដែលអានបទគម្ពីរនេះតទៅទៀត យើងមើលឃើញថា ព្រះជាម្ចាស់បានលើកតម្កើងព្រះយេស៊ូវ នៅពេលដែលព្រះអង្គបង្ហាញចេញពីលក្ខណៈសម្បត្តិដែលសំខាន់ជាងគេរបស់រូបព្រះ គឺការបម្រើដោយស្ម័គ្រចិត្ត និងដោយហ៊ានលះបង់ ។ "ដោយហេតុនេះបានជាព្រះបានលើកទ្រង់យ៉ាងខ្ពស់ ហើយបានប្រទានអោយមាននាមដ៏ប្រសើរលើសជាងអស់ទាំងនាមផង...ហើយអោយគ្រប់ទាំងអណ្តាតបានថ្លែងប្រាប់ថា ព្រះយេស៊ូវគ្រីស្ទទ្រង់ជាព្រះអម្ចាស់ សំរាប់ជាសិរីល្អដល់ព្រះដ៏ជាព្រះវរបិតា" ( ភីលីព ២:៩-១១ ) ។

ភាពជាអ្នកបម្រើត្រូវបានមើលឃើញនៅក្នុងបទគម្ពីរផ្សេងទៀតផងដែរ ។ ព្រះជាម្ចាស់បានប្រាប់ជនជាតិអ៊ីស្រាអែលថា ព្រះអង្គសព្វព្រះហឫទ័យនឹងតង្វាយរបស់ពួកគេ ដែលជាការបម្រើដល់អ្នកដែលត្រូវគេសង្កត់សង្កិន (អេសាយ ៥៨) ។ ព្រះយេស៊ូវបានប្រាប់ពួកសិស្សរបស់ព្រះអង្គថា លក្ខណៈសំគាល់ដែលប្លែកពីគេសម្រាប់អ្នកនៅក្នុងនគរព្រះគឺជាការបម្រើរបស់ពួកគេ គឺពួកគេឱ្យអាហារអ្នកដែលស្រេកឃ្លាន ឱ្យសម្លៀកបំពាក់ដល់អ្នកដែលនៅអាក្រាត ទៅមើលអ្នកឈឺ និងអ្នកជាប់គុក ( ម៉ាថាយ ២៥) ។ សាសនាដែលបរិសុទ្ធ និងគ្រប់លក្ខណ៍ត្រូវបានឱ្យនិយមន័យដោយសង្ខេបថាជាការបម្រើដល់ស្ត្រីមេម៉ាយ និងក្មេងកំព្រា គឺជាអ្នកដែលត្រូវការការការពារ ( យ៉ាកុប ១:២៧) ។ នៅកន្លែងផ្សេងទៀត ព្រះយេស៊ូវបានសង្កត់ធ្ងន់លើអាទិភាពនៃការស្រលាញ់ និងការបម្រើអ្នកជិតខាងរបស់យើងដូចខ្លួនឯង ( ម៉ាកុស ១២:៣១) ។

ឥឡូវនេះ ព្រះជាម្ចាស់ហៅកូនរបស់ព្រះអង្គឱ្យបានត្រលប់ដូចជាព្រះរាជបុត្រារបស់ព្រះអង្គ (រ៉ូម ៨:២៩) រួមទាំងភាពជាអ្នកបម្រើផង ។ មានតែជាអ្នកបម្រើប៉ុណ្ណោះ ទើបយើងអាចសម្រេចតួនាទីដែលព្រះជាម្ចាស់ប្រទានឱ្យយើងបាន ។ ដោយត្រូវបានបង្កើតមកចំរូបអង្គព្រះ យើងត្រូវបានបង្កើតមកដើម្បីបម្រើដោយលះបង់ផងដែរ ។ នៅពេលដែលយើងបម្រើដោយលះបង់ ដូចជាព្រះយេស៊ូវ យើងមានរូបព្រះពេញលេញជាងគេ ។ ហើយនៅពេលដែលយើងឆ្លុះបញ្ចាំងឱ្យឃើញរូបអង្គ និងលក្ខណៈប្រកបដោយសិរីល្អរបស់ព្រះជាម្ចាស់ ព្រះអង្គត្រូវបានលើកតម្កើង។ ព្រះអង្គក៏បានបើកសំដែងរូបព្រះអង្គផងដែរតាមរយៈពួកជំនុំ ។ ពួកជំនុំបង្ហាញចេញសេចក្តីពោរពេញរបស់ព្រះជាម្ចាស់ " ពួកជំនុំ ដែលជា

រូបកាយទ្រង់ គឺជាសេចក្ដីពោរពេញរបស់ព្រះអង្គ ដែលបំពេញគ្រប់ទាំងអស់ក្នុងទាំងអស់" (អេភេសូរ ១:២២-២៣)។ ពួកជំនុំ ដែលជារូបកាយរបស់ព្រះគ្រីស្ទ គឺជាសហគមន៍អ្នកជឿដែលបម្រើ ដែលមានរូបព្រះអង្គ និងធ្វើតាមរបៀបវារៈរបស់ព្រះអង្គ ដោយសម្របសម្រួលដល់ដំណើរការកើតជាថ្មី ការបង្កើតសិស្ស ការបណ្ដុះបណ្ដាល និងការចាត់មនុស្សឱ្យទៅក្នុងពិភពលោកធ្វើជាទូតដែលចេះបម្រើ។

គ្រីស្ទបរិស័ទជាច្រើន ជាពិសេសអ្នកដែលមានស្ថានភាពសេដ្ឋកិច្ច និងនយោបាយមិនល្អ ឬធ្លាប់ត្រូវបានគេបំពានមកលើនៅក្នុងប្រវត្តិសាស្ត្រ ជាញឹកញាប់អន់ចិត្តនឹងគំនិតដែលថា ពួកគេគួរតែជាអ្នកបម្រើ។ នៅក្នុងបរិបទរបស់ពួកគេ ភាពជាអ្នកបម្រើគឺជាភាពអាប់ឱន និងភាពបង្ខិតបង្ខំ។ ប្រាកដណាស់ ការបម្រើដោយបង្ខិតបង្ខំអាចជាអំពើទាសភាព។ ការបម្រើអាចជាអំពើអាប់ឱនដែលត្រូវតែធ្វើដោយសារសេដ្ឋកិច្ចលំបាក។ ការបម្រើនេះអាចបង្ខំមកលើមនុស្សមិនស្ម័គ្រចិត្តពីសំណាក់អ្នកមានអំណាច។ ប៉ុន្តែនេះមិនមែនជាការបម្រើដោយស្ម័គ្រចិត្ត និងដោយហ៊ានលះបង់ដែលមាននិយាយនៅក្នុងព្រះគម្ពីរទេ។ នេះមិនមែនជារូបព្រះដែលជាសិទ្ធិកូនច្បងរបស់បុត្រាបុត្រីរបស់ព្រះអង្គទេ។

ព្រះជាម្ចាស់បង្គាប់ឱ្យបម្រើ ពីព្រោះការបម្រើបង្ហាញចេញ និងបណ្ដាលមកពីលក្ខណៈសម្បត្តិដែលអស្ចារ្យជាងគេបំផុតរបស់ព្រះអង្គ គឺជាសេចក្ដីស្រលាញ់។ សេចក្ដីស្រលាញ់មិនត្រូវបានកត់ត្រាជាការបង្ហាញចេញរូបព្រះទេ ពីព្រោះសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញច្បាស់បំផុតតាមរយៈពួកជំនុំ និងអ្នកនៅក្នុងពួកជំនុំ នៅពេលដែលពួកគេបម្រើ។ ពិតណាស់ លោកយ៉ូហានបានសួរថា ធ្វើដូចម្ដេចឱ្យសេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់អាចមាននៅក្នុងអ្នកដែលនិយាយថា ខ្លួនមានសេចក្ដីស្រលាញ់ ប៉ុន្តែមិនបម្រើបងប្អូនដែលខ្វះខាតនោះបាន (១ យ៉ូហាន ៣:១៧)។ ព្រះជាម្ចាស់ចង់បំពេញយើង ឱ្យពេញដោយសេចក្ដីស្រលាញ់របស់ព្រះអង្គ ដើម្បីឱ្យអ្នកមើលដឹងថា សេចក្ដីស្រលាញ់ដែលយើងបង្ហាញចេញឱ្យពួកគេ ឃើញគឺជា *សេចក្ដីស្រលាញ់របស់ព្រះជាម្ចាស់* ។ បទគម្ពីរបង្ហាញថា របៀបចម្បងនៅក្នុងការបង្ហាញចេញសេចក្ដី ស្រលាញ់របស់យើងចំពោះព្រះជាម្ចាស់ គឺតាមរយៈការស្រលាញ់អ្នកដទៃទៀត (លូកា ១០, អេសាយ ៥៨, យ៉ាកុប ១, យ៉ាកុប ២, ១យ៉ូហាន ៣)។ យើងមិនត្រូវធ្វើឱ្យមនះសិការបស់យើងភ្លេចផែនការរបស់ព្រះជាម្ចាស់ដែលថា យើងដែលជារូបកាយរបស់ព្រះគ្រីស្ទ គឺជាឧបករណ៍ដ៏ចម្បងដើម្បីឱ្យអំណាចបំផ្លាស់បំប្រែជីវិតរបស់ព្រះជាម្ចាស់ហូរមកតាមនោះ!

ការបម្រើដោយសេចក្ដីស្រលាញ់ និងដោយហ៊ានលះបង់ប្រហែលជាលក្ខណៈសម្បត្តិដែលពិបាកជាងគេបំផុតរបស់រូបអង្គព្រះ។ ហេតុអ្វី? ការបម្រើអ្នកដទៃ ដូចដែលព្រះគ្រីស្ទបានបម្រើ មានន័យថា បោះបង់ចោលសិទ្ធិ និងឋានៈរបស់ខ្លួនយើង។ នោះមានន័យថា បដិសេធខ្លួនឯងដើម្បីអ្នកដទៃទៀត។ ការបម្រើដូចជាព្រះយេស៊ូវបានបម្រើ *មិនអាចធ្វើកើតទេ* លើកលែងតែមានព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះអង្គគង់នៅក្នុងប៉ុណ្ណោះ ទើបអាចធ្វើកើត។ ការបម្រើដូចជាព្រះគ្រីស្ទមិនត្រឹមតែអាចធ្វើកើតប៉ុណ្ណោះទេ ថែមទាំងនាំឱ្យបានសម្រេចគោលបំណងរបស់ព្រះជាម្ចាស់ នៅពេលដែលព្រះអង្គបានបង្កើតយើងមកឱ្យចំរូបអង្គទ្រង់ថែមទៀតផង។

ពួកជំនុំត្រូវជួយសមាជិករបស់ខ្លួនឱ្យមានការយល់ដឹងត្រឹមត្រូវតាមព្រះគម្ពីរឡើងវិញអំពីភាពជាអ្នកបម្រើ។ តើយើងត្រូវធ្វើយ៉ាងដូចម្ដេច ប្រសិនបើយើងមិនបានធ្វើជាអ្នកបម្រើដូចន័យនៅក្នុងព្រះគម្ពីរនោះ? នៅត្រង់កន្លែងដែលយើងបានបម្រើឱ្យផលប្រយោជន៍ខ្លួនឯង យើងត្រូវបែរត្រលប់ក្រោយ ដើរតាមទិសផ្ទុយពីមុន គឺបម្រើឱ្យផលប្រយោជន៍របស់អ្នកដទៃវិញ។ ការបម្រើនៅក្នុងព្រះគម្ពីរមិនអាចធ្វើកើតទេ បើគ្មានព្រះគ្រីស្ទគង់នៅក្នុងទេនោះ ប៉ុន្តែការបម្រើនៅក្នុងព្រះគម្ពីរអាចធ្វើកើតតាមរយៈអំណាចព្រះចេស្ដារបស់ព្រះវិញ្ញាណនៃព្រះ។ លោកប៉ុលបានរំលឹកអ្នកអានសំបុត្ររបស់លោកថា ព្រះជាម្ចាស់ និងមនុស្សធ្វើការរួមគ្នា ដើម្បីសម្រេចគោលបំណងរបស់ព្រះជាម្ចាស់។

> *...ចូរបង្ហើយសេចក្ដីសង្គ្រោះរបស់អ្នករាល់គ្នាដោយកោតខ្លាច ហើយញាប់ញ័រចុះ...គឺជាព្រះហើយដែលបណ្ដាលចិត្តអ្នករាល់គ្នាអោយមានទាំងចំណង់ចង់ធ្វើ ហើយអោយបានប្រព្រឹត្តតាមបំណងព្រះហឫទ័យទ្រង់ដែរ"* ( ភីលីព ២:១២-១៣)។

## វិន័យ និងការហាត់អនុវត្ត

ប្រសិនបើសេចក្ដីទាំងអស់នេះពិតមែននោះ តើយើងឆ្លុះបញ្ចាំងលក្ខណៈសម្បត្តិមួយនេះរបស់រូបអង្គព្រះយ៉ាងដូចម្ដេច? វិធីមួយគឺអភិវឌ្ឍអ្វីដែលព្រះជាម្ចាស់បានដាក់នៅក្នុងយើង។ ប្រាកដណាស់ ការអភិវឌ្ឍន៍អត្តចរិតដូចជាព្រះគ្រីស្ទតម្រូវឱ្យមានទម្លាប់ថ្មី និងជំនាញថ្មី។ ដើម្បីអភិវឌ្ឍទម្លាប់ថ្មី និងជំនាញថ្មី យើងត្រូវតែមានវិន័យ។ ហេតុអ្វីត្រូវចុះចូលនឹងវិន័យ? កីឡាករដែលចង់ចាប់យកអាជីពត្រូវតែដាក់វិន័យខ្លួនតាមកាលវិភាគហ្វឹកហាត់យ៉ាងតឹងរ៉ឹង និងហាត់អនុវត្តមិនចេះចប់មិនចេះហើយ។ សិស្សទាំងអស់ដែលចង់រៀនចប់ដោយបានពិន្ទុខ្ពស់ជាងគេ និងមានការងារល្អត្រូវដាក់វិន័យខ្លួនឱ្យខិតខំប្រឹងប្រែងរៀនសូត្ររយៈពេលរាប់ឆ្នាំ។ នៅទីបំផុត មនុស្សចុះចូលនឹងវិន័យថ្មី ពីព្រោះលទ្ធផលដែលពួក គេចង់បាននោះសំខាន់ខ្លាំងណាស់សម្រាប់ពួកគេ។

ដូចគ្នាដែរ វិន័យ និងការបណ្ដុះបណ្ដាលចាំបាច់ខ្លាំងណាស់សម្រាប់ការរីកចម្រើនឡើងខាងឯការគោរពប្រតិបត្តិដល់ព្រះ។ លោកប៉ុលបានហៅកូនសិស្សវ័យក្មេងរបស់លោក គឺលោកធីម៉ូថេ ឱ្យបង្ហាត់ខ្លួនខាងឯវិញ្ញាណ "ដ្បិតការបង្ហាត់ខ្លួនប្រាណ នោះមានប្រយោជន៍តែបន្តិចទេ តែមានសេចក្ដីសន្យាឱ្យបានជីវិតនៅជាប់តឡូវនេះ ហើយទៅខាងនាយផង" (១ ធីម៉ូថេ ៤:៨)។ មែនហើយ វិន័យតម្រូវឱ្យមានការលះបង់ និងការខិតខំប្រឹងប្រែង! នេះមានប្រយោជន៍សម្រាប់អ្នកដែលកំពុងទទួលការបម្រើ ហើយនាំយើងឱ្យខិតចូលកាន់តែជិតគោលបំណងដែលព្រះជាម្ចាស់បានបង្កើតយើងមក។

## វិន័យខាងឯសេចក្ដីស្រលាញ់

យើងផ្ដល់ជូនលំហាត់មួយដើម្បីជួយដាក់វិន័យយើងឱ្យកាន់តែត្រលប់ដូចជាលក្ខណៈសម្បត្តិបម្រើរបស់រូបអង្គព្រះ ហើយលំហាត់នេះគឺជាវិន័យខាងឯសេចក្ដីស្រលាញ់ គឺជាវិន័យខាងវិញ្ញាណ។ វិន័យនេះត្រូវបានរៀបចំឡើង

ដើម្បីជួយអ្នកដើរតាមព្រះគ្រីស្ទឱ្យហាត់បង្ហាញចេញសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ តាមរយៈការបម្រើអ្នកដទៃទៀត! វិន័យខាងឯវិញ្ញាណដទៃទៀត ដូចជាការអធិស្ឋាន ការអានព្រះគម្ពីរ ការសញ្ជឹងគិត ការទន្ទេញខគម្ពីរ និងការតមអត់ មានគោលបំណងទៅរកព្រះជាម្ចាស់ ដោយពង្រឹងទំនាក់ទំនងរវាងសិស្ស និងព្រះអម្ចាស់របស់ពួកគេ។ វិន័យនេះសង្កត់ធ្ងន់ទៅរកមនុស្ស ដើម្បីឱ្យសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់ដែលនៅក្នុងយើងតាមរយៈការនៅជាប់ជាមួយព្រះគ្រីស្ទ បង្ហាញចេញមកក្រៅដល់មនុស្សដទៃទៀត។

វិន័យខាងឯសេចក្តីស្រលាញ់សាមញ្ញទេ។ អ្នកដែលប្រើវិន័យនេះរកមើលឱកាសដើម្បីបម្រើ បន្ទាប់មក បម្រើ! វិន័យនេះតម្រូវឱ្យមានការប្តេជ្ញាចិត្ត និងទំនាក់ទំនងជិតស្និទ្ធជាមួយព្រះជាម្ចាស់ ដើម្បីឱ្យកំឡាំងរបស់ព្រះអង្គអាចធ្វើការតាមរយៈយើងបាន។ ទោះបីគិតទៅសាមញ្ញក៏ដោយ ការហ្វឹកហាត់វិន័យនេះនឹងបំផ្លាស់បំប្រែជីវិតមនុស្ស។

វិន័យខាងឯសេចក្តីស្រលាញ់ក៏មានលក្ខណៈអនុវត្តជាក់ស្តែងផងដែរ។ វិន័យនេះជួយអ្នកជឿម្នាក់ៗឱ្យឆ្លុះបញ្ចាំងឱ្យឃើញពីអត្តចរិតបម្រើរបស់ព្រះគ្រីស្ទនៅក្នុងផ្នែកទាំងបួនដែលព្រះជាម្ចាស់យកព្រះហឫទ័យទុកដាក់ (ប្រាជ្ញា សាច់ឈាម វិញ្ញាណ សង្គម) នៅក្នុងពិភពដែលពួកគេរស់នៅ (គ្រួសារ ពួកជំនុំ និងសហគមន៍)។ សេចក្តី ស្រលាញ់ និងគោលបំណងរបស់ព្រះជាម្ចាស់ត្រូវបានបង្ហាញចេញមកឱ្យឃើញ នៅពេលដែលយើងបម្រើអ្នកដទៃទៀត នៅក្នុងបរិបទ និងផ្នែកផ្សេងៗនៅក្នុងជីវិត។ មនុស្សដែលយើងបម្រើនៅក្នុងវិន័យនេះ ជាញឹកញាប់ គឺជាមនុស្សដែលយើងស្គាល់ និងជួបជាមួយតាមធម្មតានៅក្នុងជីវិតរស់នៅប្រចាំថ្ងៃ គឺអ្នកនៅក្នុងគ្រួសាររបស់យើង ពួកជំនុំរបស់យើង កន្លែងធ្វើការរបស់យើង សាលារបស់យើង និងសហគមន៍របស់យើង។ ការបម្រើរបស់យើងដល់ពួកគេអាចមានលក្ខណយ៉ាងសាមញ្ញ។ យើងមិនត្រូវការលុយ ពេលវេលា ទេពកោសល្យ បុគ្គលិក ឬជំនាញច្រើនទេ។ យើងត្រូវឆ្លុះបញ្ចាំងឱ្យឃើញរូបភាពរបស់ព្រះគ្រីស្ទ តាមរយៈការបម្រើពួកគេដោយលះបង់។ សូមគិតអំពីឥទ្ធិពលដែលអាចកើតមានមកលើពិភពលោកនៅជុំវិញពួកគេ តាមរយៈអ្នកជឿដែលបម្រើម្នាក់ទល់នឹងម្នាក់។ បន្ទាប់មក គិតអំពីឥទ្ធិពលដែលអាចកើតមានតាមរយៈអ្នកជឿ *ជាច្រើន*ដែលម្នាក់ៗមានសេចក្តីស្រលាញ់ និងស្តាប់បង្គាប់ នៅពេលដែលពួកគេបម្រើមនុស្សដែលព្រះជាម្ចាស់នាំមកក្នុងជីវិតរបស់ពួកគេ!

អ្នកដែលហាត់អនុវត្តវិន័យខាងឯសេចក្តីស្រលាញ់មានការរីកចម្រើនឡើងតាមរបៀបជាច្រើន។ ពួកគេបង្ហាញពីភាពរវាសដឹងសេចក្តីត្រូវការរបស់អ្នកដទៃទៀត។ ពួកគេរៀនឆ្លើយតបដោយស្តាប់បង្គាប់ចំពោះសេចក្តីត្រូវការរបស់មនុស្សដទៃទៀតតាមរបៀបដែលធំ និងមានតុល្យភាព។ ពួកគេមានភាពឆ្នៃប្រឌិតនៅក្នុងការបម្រើរបស់ពួកគេ។ ពួកគេបង្ហាញឱ្យឃើញពីលទ្ធភាពបង្អុលបង្ហាញទៅរកព្រះជាម្ចាស់ជាប្រភពនៃសេចក្តីស្រលាញ់របស់យើង។ ការបម្រើរបស់ពួកគេដល់មនុស្សដទៃទៀតត្រូវបានដៅសំគាល់ដោយព្រះគុណ។ ពួកគេកំពុងតែអភិវឌ្ឍរបៀបរស់នៅដែលចេះបម្រើដោយសេចក្តីស្រលាញ់។ ហើយសំខាន់ជាងគេបំផុតនោះ ពួកគេមានភាពស្និទ្ធស្នាលកាន់តែខ្លាំងឡើងជាមួយព្រះជាម្ចាស់។

## លំហាត់វិន័យខាងឯសេចក្តីស្រលាញ់

វិន័យខាងឯសេចក្តីស្រលាញ់ប្រើក្រឡាចត្រង្គ ដើម្បីកត់ត្រាការបម្រើតាមបែបតូចៗដល់គ្រួសារ អ្នកជឿ និង "អ្នកជិតខាង"របស់យើងដែលមិនមែនជាគ្រីស្ទបរិស័ទ។ ក្រឡាចត្រង្គនេះផ្តល់ឱ្យយើងមានព្រំដែនយ៉ាងទូលំទូលាយសម្រាប់ការបម្រើ។ ក្រោយមក ការបម្រើនិមួយៗត្រូវបានកត់ត្រានៅក្នុងទិន្នានុប្បវត្តិខ្លីមួយ ដើម្បីឱ្យយើងអាចសញ្ជឹងគិតមើលអំពីការបម្រើរបស់យើងបាន និងមានទំនួលខុសត្រូវនៅចំពោះអ្នកណែនាំ ឬក្រុមតូច។ យើងប្រើឧបករណ៍ដ៏ចម្បងរបស់លំហាត់នេះ ដើម្បីរៀបចំផែនការ អនុវត្ត សញ្ជឹងគិត និងមានទំនួលខុសត្រូវ។

សូមឱ្យព្រះជាម្ចាស់ប្រើវិន័យខាងឯសេចក្តីស្រលាញ់ ជួយយើង និងអ្នកដែលយើងបណ្តុះបណ្តាលឱ្យបានត្រលប់ដូចជាព្រះគ្រីស្ទកាន់តែខ្លាំងឡើង ជារូបធ្លុះអំពីការបម្រើដោយស្ម័គ្រចិត្ត ដោយហ៊ានលះបង់ និងដោយសេចក្តីស្រលាញ់របស់ព្រះជាម្ចាស់។ សូមឱ្យវិន័យនេះពង្រីកលទ្ធភាពរបស់យើងនៅក្នុងការមើលឃើញ និងឆ្លើយតបចំពោះសេចក្តីត្រូវការរបស់អ្នកដែលនៅក្នុងពិភពផ្សេងៗរបស់យើង និងសូមឱ្យវិន័យនេះជួយយើងអភិវឌ្ឍរបៀបរស់នៅដែលចេះបម្រើដែលឆ្លុះបញ្ចាំងឱ្យឃើញរូបអង្គរបស់ព្រះ។ សូមឱ្យយើងមានភាពស្និទ្ធស្នាលកាន់តែខ្លាំងឡើងជាមួយព្រះវរបិតារបស់យើង នៅពេលដែលយើងស្រលាញ់មនុស្សដទៃទៀតដោយអំណាច និងសេចក្តីស្រលាញ់ដ៏បរិបូររបស់ព្រះជាម្ចាស់នៅក្នុងយើង និងនៅពេលដែលយើងស្តាប់បង្គាប់តាមបញ្ញត្តិដែលសំខាន់ជាងគេបំផុត គឺស្រលាញ់ព្រះជាម្ចាស់ឱ្យអស់អំពីចិត្ត អស់អំពីព្រលឹង និងអស់អំពីគំនិត តាមរយៈការស្រលាញ់អ្នកជិតខាងរបស់យើងដូចខ្លួនឯង (ម៉ាថាយ ២២:៣៦-៣៨)។ ហើយ សូមឱ្យអ្នកដែលយើងបម្រើបានយល់ដឹងថ្មីៗ និងកាន់តែច្រើនឡើងអំពីព្រះជាម្ចាស់ និងសេចក្តីស្រលាញ់របស់ព្រះអង្គ តាមរយៈរូបអង្គទ្រង់នៅក្នុងយើង។

សូមមើលមេរៀនអមមកជាមួយ ដើម្បីចូលរួមផ្ទាល់ខ្លួន និងលើកទឹកចិត្តអ្នកដទៃទៀត! វិន័យខាងឯសេចក្តីស្រលាញ់គឺជាឧបករណ៍ដ៏មានប្រយោជន៍មួយសម្រាប់អ្នកដើរតាមព្រះគ្រីស្ទនៅជុំវិញពិភពលោក ដែលបានដើរតាមផ្លូវបង្កើតសិស្ស និងបម្រើនេះ។ សូមស្តាប់ពីពួកគេមួយចំនួន និងអានរឿងអំពីការបម្រើរបស់ពួកគេ ដោយជ្រើសរើសរឿងនៅគេហទំព័រ www.harvestfoundation.org ។

*By Bob Moffitt, Harvest Foundation*

*Last edited by Nadia Chandler and Karla Tesch, August, 2007.*

*Copyright 2007 by the Disciple Nations Alliance*

*701 N. 1st Street Phoenix, AZ  85004*

*email: bmoffitt@harvestfoundation.org*

*www.harvestfoundation.org and www.disciplenations.org*

*ការអនុញ្ញាតៈ លោកអ្នកត្រូវបានអនុញ្ញាត និងលើកទឹកចិត្តឱ្យថតចម្លង និងចែកចាយមេរៀននេះតាមទម្រង់ណាមួយក៏បាន តែសូមកុំកែន័យមេរៀន កុំគិតថ្លៃហួសពីលោកអ្នកចំណាយ និងកុំថតចម្លងច្រើនជាង ១000 ច្បាប់ ។*

## ធនធានល្អដែលបានផ្តល់ជាយោបល់ជូនៈ

Harvest Website: www.harvestfoundation.org . Sections: Materials – LDTP II, Stories, Disciplines of Love

Moffitt, Bob and Karla Tesch. *If Jesus Were Mayor*. Monarch Books, 2007.